ការដាក់ពាក្យស្នើសុំរៀបចំ
សិក្ខាសាលាអនុវត្តស្តីពី ឧបករណ៍មិនបង្កទំនាស់ (Do No Harm)

I. សាវតា

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា(គ.ស.ក) គឺជាអង្គការសមាជិកភាពឈានមុខគេដែលមានសមាជិកជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក(DNGOs) និងអង្គការបរទេស (FNGOs) សរុបចំនួន១៨៣ នៅក្នុងប្រទេសកម្ពុជា។ គ.ស.ក បានបង្កើត និងអនុវត្តកម្មវិធីមជ្ឈមណ្ឌលអភិបាលកិច្ច (GHP) ២០២៤-២០២៨ ដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ បង្កើតបរិយាកាសអំណោយផលល្អសម្រាប់អង្គការសង្គមស៊ីវិល និងដោះស្រាយបញ្ហាប្រឈមក្នុងការអភិវឌ្ឍន៍នៅកម្ពុជា។

តាមរយៈវិធីសាស្ត្រការងាររបស់ខ្លួន គ.ស.ក នឹងលើកទឹកចិត្តឲ្យមានការរួមបញ្ចូលនូវឧបករណ៍មិនបង្កទំនាស់ (DNH) និងវិធីសាស្ត្រផ្អែកលើសិទ្ធិ (RBA) ទៅក្នុងអង្គការ និងសកម្មភាពរបស់អង្គការដៃគូ និងសមាជិករបស់ខ្លួន។ វិធីសាស្ត្រនេះសង្កត់ធ្ងន់ទៅលើការបង្រួមឲ្យបានជាអប្បបរមានូវផលជៈជាអវិជ្ជមានដែលមិនបានរំពឹងទុក និងការបង្កើនផលជៈជាវិជ្ជមាននៅក្នុងអន្តរាគមន៍ ឬគម្រោងណាមួយ។ សកម្មភាពជាបន្តបន្ទាប់នឹងត្រូវរៀបចំឡើងដើម្បីលើកកម្ពស់ចំណេះដឹង សមត្ថភាពសម្រាប់អង្គការសង្គមស៊ីវិលអំពីឧបករណ៍ DNH មានដូចជា សិក្ខាសាលាផ្សព្វផ្សាយ សិក្ខាសាលាស្តីពីការអនុវត្ត ការបង្វឹក ការចែករំលែកការរៀនសូត្រ/ការឆ្លុះបញ្ចាំងការអនុវត្តតាមរយៈវេទិកាសហគមន៍នៃអ្នកអនុវត្តឧបករណ៍មិនបង្កទំនាស់ (DNH) ជាដើម។

II. គោលបំណង

អង្គការដែលបានចូលរួម នឹងប្រើប្រាស់ឧបករណ៍DNH ដើម្បីវិភាគយុទ្ធសាស្ត្រ/កម្មវិធី/គម្រោងរបស់ពួកគេដោយ៖ ១). វិភាគបរិបទនៃទំនាស់ កំណត់កត្តាបែកបាក់ និងកត្តាផ្សារភ្ជាប់ ២). វិភាគគំរូនៃផលជៈពីអន្តរាគមន៍របស់ពួកគេ ៣). បង្កើតជម្រើសក្នុងការអនុវត្តគម្រោង/កម្មវិធី/យុទ្ធសាស្ត្រ និង ៤). បង្កើតក្របខ័ណ្ឌ DNH ។

III. ប្រធានបទ

ពេលវេលា	ថ្ងៃទី១	ថ្ងៃទី២	ថ្ងៃទី៣
ព្រឹក	❖ រំឭកពីប្រវត្តិ និងមេរៀនឧបករណ៍មិនបង្កទំនាស់	❖ អនុវត្តជំហានទី២ ទី៣៖ កំនត់កត្តាបែកបាក់ និងកត្តាផ្សារភ្ជាប់	❖ អនុវត្តជំហានទី៥៖ កំនត់សណ្ឋានផលជៈ
ល្ងាច	❖ អនុវត្តជំហានទី១៖ ការវិភាគបរិបទនៃទំនាស់	❖ អនុវត្តជំហានទី៤៖ វិភាគសេចក្តីលម្អិតនៃកម្មវិធី	❖ អនុវត្តជំហានទី៦ ទី៧៖ តើអាចមាន

			ជម្រើសផ្សេងទៀត ឬទេ? អនុវត្តជម្រើស

IV. វិធីសាស្ត្រ

សិក្ខាសាលាអនុវត្ត DNH នឹងត្រូវបានរៀបចំដោយឡែកពីគ្នាសម្រាប់ស្ថាប័ននីមួយៗ ដើម្បីវិភាគកម្មវិធី/គម្រោងផ្ទាល់ខ្លួនរបស់ពួកគេ។ ប្រសិនបើអង្គការផ្សេងគ្នា តែមានគម្រោង/កម្មវិធីស្រដៀងគ្នា ពួកគេអាចចូលរួមជាមួយគ្នាបាន ប្រសិនបើពួកគេចង់ និងយល់ព្រមរៀបចំជាមួយគ្នា។

V. អាហារូបករណ៍សម្រាប់សិក្ខាសាលាអនុវត្តឧបករណ៍មិនបង្កទំនាស់

គ.ស.ក នឹងផ្តល់អាហារូបករណ៍ចំនួន ១០០% នៃថ្លៃសេវាគ្រូបណ្តុះបណ្តាល សម្រាប់ការសម្របសម្រួលសិក្ខាសាលាអនុវត្តនេះ ។

អង្គការដែលស្នើសុំនឹងត្រូវចេញចំណាយសម្រាប់ការរៀបចំទីកន្លែង សំភារ: ព្រមទាំងការចំណាយរបស់សិក្ខាកាមផ្សេងៗទៀត (ប្រសិនបើចាំបាច់)។

VI. ការជ្រើសរើសពេលវេលា

សិក្ខាសាលាអនុវត្តសម្រាប់អង្គការដែលបានស្នើសុំ នឹងត្រូវរៀបចំធ្វើឡើងចាប់ពី ៣ទៅ៥ថ្ងៃ និងនៅរវាងខែកញ្ញា ដល់ ខែវិច្ឆិកា ឆ្នាំ២០២៤ ទៅតាមពេលវេលាដែលបានព្រមព្រៀងគ្នា។

VII. ការជួយសម្របសម្រួលរបស់អង្គការស្នើសុំ

1. ផ្តល់បុគ្គលិកម្នាក់ជាជនបង្គោលឧបករណ៍មិនបង្កទំនាស់ក្នុងអង្គការ និងធានាការចូលរួមរបស់បុគ្គលិកនោះក្នុងកំឡុងពេលអនុវត្តគម្រោង។
2. ផ្តល់ឯកសារពាក់ព័ន្ធ ទាន់ពេលវេលាតាមការស្នើសុំ ដើម្បីជាជំនួយដល់គ្រូបណ្តុះបណ្តាល។ ទោះជាយ៉ាងណា ប្រការនេះអាស្រ័យលើគោលការណ៍ស្មគ្រចិត្ត។
3. មានឆន្ទ:ក្នុងការរៀបចំសិក្ខាសាលាអនុវត្តឧបករណ៍មិនបង្កទំនាស់នៅក្នុងអង្គការរបស់ខ្លួន។
4. មានឆន្ទ:ក្នុងការចូលរួមវគ្គបង្វឹក និងវេទិកាសហគមន៍អនុវត្ត ឧបករណ៍មិនបង្កទំនាស់ ដែលរៀបចំ និងសម្របសម្រួលដោយ គ.ស.ក។
5. មានឆន្ទ:ក្នុងការអនុវត្តមេរៀនដែលទទួលបានពីវគ្គបណ្តុះបណ្តាល និងវគ្គបង្វឹក។

VIII. ការដាក់ពាក្យស្នើសុំ និងកាលបរិច្ឆេទឈប់ទទួលពាក្យ

អង្គការដែលមានចំណាប់អារម្មណ៍ សូមបំពេញទម្រង់ស្នើសុំ និងផ្ញើមក គ.ស.ក ត្រឹមថ្ងៃទី **០៤ ខែកញ្ញា ឆ្នាំ២០២៤** តាមរយ:អាសយដ្ឋានសារអេឡិចត្រូនិចៈ sreypich.phok@ccc-cambodia.org

ទំនាក់ទំនងព័ត៌មានបន្ថែម:

អ្នកស្រី ភោគ ស្រីពេជ្រ
មន្ត្រីអភិវឌ្ឍសមត្ថភាព
ទូរស័ព្ទ: ០៨៩ ៨១ ៨១ ៧៦/ ០៧០ ៦១ ៨១ ៧៦
អ៊ីម៉ែល: sreypich.phok@ccc-cambodia.org